**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៨៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែប្រែដែនជម្រកសត្វព្រៃតាតៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាស

- បានឃើញអនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៨០ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃតាតៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកែប្រែដែនជម្រកសត្វព្រៃតាតៃ ពីផ្ទៃដីទំហំ១៤៤ ២៧៥(មួយសែនបួនម៉ឺនបួនពាន់ពីររយចិតសិបប្រាំ)ហិកតា មកផ្ទៃដីទំហំ១៤៤ ៥៣៩(មួយសែនបួនម៉ឺនបួនពាន់ប្រាំរយសាមសិបប្រាំបួន)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តកោះកុង ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា(តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984)ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ផ្ទៃដីដែនជម្រកសត្វព្រៃតាតៃខាងលើនេះ បានមកពីការបូកបញ្ចូលផ្ទៃដីទំហំ១៤៤ ២៧៥(មួយសែនបួនម៉ឺនបួនពាន់ពីររយចិតសិបប្រាំ)ហិកតា ដែលមានចែងក្នុងអនុក្រឹត្យលេខ៨០ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃតាតៃ និងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញ ដែលមានផ្ទៃដីទំហំ២៦៤(ពីររយហុកសិបបួន)ហិកតា ដែលមានចែងក្នុងអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖
- ធានាឱ្យមានការថែទាំទីជម្រកសត្វព្រៃនិងប្រព័ន្ធអេកូឡូស៊ី ព្រមទាំងធានាឱ្យមានការបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វ រុក្ខជាតិ និងជីវៈចម្រុះ
- រក្សាលំនឹងបរិស្ថាននិងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ផ្តល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងសហគមន៍មូលដ្ឋាន ដើម្បីរួមចំណែកក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការការពារធនធានធម្មជាតិ និងការរស់នៅដោយចីរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃតាតៃ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តកោះកុង ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ .-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ដែលអនុលោមតាមអនុក្រឹត្យស្តីពីការបង្កើតដែនជម្រកសត្វព្រៃតាតៃ និងអនុក្រឹត្យស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៥ រោច ខែ បឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៨៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

## ផែនទីដែនជម្រកសត្វព្រៃតាតៃ ស្ថិតក្នុងភូមិសាស្ត្រខេត្តកោះកុង






**សញ្ញាសម្គាល់**

- ចំណុចនិយាមកា
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

មាត្រដ្ឋាន 1:250,000

0 2.5 5 10 km

Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984

**ដែនជម្រកសត្វព្រៃតាតៃ**

មានផ្ទៃដីទំហំ ១៤៤ ៥៣៥ហិកតា

**ប្រភពទិន្នន័យ**

ព្រំប្រទល់តំបន់ការពារធម្មជាតិ : ក្រសួងបរិស្ថាន

ព្រំប្រទល់រដ្ឋបាល : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០២១)

រូបភាព : Google Earth

ផលិតដោយ : នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រនៃក្រសួងបរិស្ថាន

ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៨៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

ចំណុចនិយាមការនៃផែនទីដែនជម្រកសត្វព្រៃតាតៃ

| ID | X | Y |
|---|---|---|
| 1 | 291623 | 1296562 |
| 2 | 300579 | 1291281 |
| 3 | 308398 | 1286828 |
| 4 | 310072 | 1288761 |
| 5 | 310990 | 1287667 |
| 6 | 312771 | 1289046 |
| 7 | 314103 | 1290065 |
| 8 | 317242 | 1284516 |
| 9 | 320104 | 1279243 |
| 10 | 319226 | 1276791 |
| 11 | 317843 | 1274774 |
| 12 | 315386 | 1273416 |
| 13 | 312751 | 1272048 |
| 14 | 311357 | 1270761 |
| 15 | 311007 | 1268357 |
| 16 | 311707 | 1268212 |
| 17 | 313769 | 1268396 |
| 18 | 315141 | 1268896 |
| 19 | 317234 | 1268899 |
| 20 | 318708 | 1268133 |
| 21 | 321214 | 1268736 |
| 22 | 323720 | 1269173 |
| 23 | 323819 | 1270849 |
| 24 | 324557 | 1272132 |
| 25 | 326116 | 1273578 |
| 26 | 331561 | 1273568 |
| 27 | 337961 | 1273556 |
| 28 | 337144 | 1271351 |
| 29 | 337517 | 1268881 |
| 30 | 337736 | 1265963 |
| 31 | 337194 | 1262745 |
| 32 | 338252 | 1259600 |
| 33 | 340322 | 1256952 |
| 34 | 340962 | 1254988 |
| 35 | 340212 | 1253729 |
| 36 | 338080 | 1253654 |
| 37 | 335577 | 1253260 |
| 38 | 334480 | 1252765 |
| 39 | 334275 | 1250959 |
| 40 | 333863 | 1249900 |
| 41 | 332657 | 1247275 |
| 42 | 331627 | 1244735 |

| ID | X | Y |
|---|---|---|
| 43 | 330185 | 1242791 |
| 44 | 330236 | 1240477 |
| 45 | 331179 | 1239179 |
| 46 | 332767 | 1238025 |
| 47 | 333655 | 1237644 |
| 48 | 331787 | 1236536 |
| 49 | 329490 | 1236236 |
| 50 | 326615 | 1236780 |
| 51 | 323738 | 1237407 |
| 52 | 322668 | 1239817 |
| 53 | 321416 | 1242397 |
| 54 | 318493 | 1247626 |
| 55 | 315799 | 1252788 |
| 56 | 312970 | 1254055 |
| 57 | 311432 | 1256602 |
| 58 | 309620 | 1258519 |
| 59 | 306649 | 1258918 |
| 60 | 304098 | 1260388 |
| 61 | 302072 | 1262248 |
| 62 | 299760 | 1264138 |
| 63 | 298021 | 1265969 |
| 64 | 295149 | 1268268 |
| 65 | 297316 | 1269911 |
| 66 | 295623 | 1271462 |
| 67 | 296758 | 1273916 |
| 68 | 297642 | 1276691 |
| 69 | 296429 | 1278590 |
| 70 | 294247 | 1280254 |
| 71 | 292359 | 1282059 |
| 72 | 289844 | 1281626 |
| 73 | 288329 | 1281464 |
| 74 | 287073 | 1283584 |
| 75 | 284605 | 1283762 |
| 76 | 282026 | 1284780 |
| 77 | 279691 | 1285328 |
| 78 | 278339 | 1287924 |
| 79 | 277790 | 1290748 |
| 80 | 278465 | 1292454 |
| 81 | 280240 | 1294686 |
| 82 | 282630 | 1296434 |
| 83 | 285272 | 1296844 |
| 84 | 287502 | 1295113 |